# ទេវតាភាសិត
# និង
# ពុទ្ធភាសិត

រៀបរៀងនិពន្ធជាកាព្យ តាមគាថា

ដោយ

ព្រះវិន័យធរ ធម្មិស្សរោ ឯក-ញឹម

វត្តពិកខូរង្សី សង្កាត់លេខ ២ ភ្នំពេញ

តាមសេចក្តីនិមន្ត

ឧបាសិកា សៀវ-ជោ

ព្រមទាំងធិតា

បោះពុម្ព បែកជាធម្មទាន

ក្នុងឧកាស ធ្វើបុណ្យធ្ងន់

ពុទ្ធិកវិទ្យាល័យមួយខ្នង

នៅវត្តពោធិវាល ខេត្តបាត់ដំបង

ព. ស. ២៥០៤ គ. ស. ១៩៦១

CA 43

# ទេវតាភាសិត និង ពុទ្ធភាសិត

រៀបរៀងនិពន្ធជាកាព្យ តាមគាថា

ដោយ

ព្រះវិន័យធរ ធម្មិស្សរោ ឯក-ញឹម

វត្តពិកខ្វរង្សី សង្កាត់លេខ ២ ភ្នំពេញ

តាមសេចក្ដីនិមន្ត

ឧបាសិកា សៀវ-ថោ

ព្រមទាំងធិតា

បោះពុម្ព

ចែកជាធម្មទាន

ក្នុងឱកាស ធ្វើបុណ្យឆ្លង

ពុទ្ធិកវិទ្យាល័យមួយខ្នង

នៅវត្តពោធិវាល ខេត្តបាត់ដំបង

ព. ស. ២៥០៤ គ. ស. ១៩៦១



រូបបុស្បុក
ព្រមទាំងព្រះជី
សាងពីលោហធាតុ



កុដិសមាធិ



ពុទ្ធិកវិទ្យាល័យ
អ៊ឹង - ឈួង

# បុណ្យឆ្លងពុទ្ធិកវិទ្យាល័យ

និពន្ធពាក្យប្រាំពីរ

ខ្ញុំម្ចាស់ទីជាឧបាសិកា   គោតនាមាឈ្មោះសៀវ-ជោ
មានបុត្របេតនាកាត់សោភោ   ពុំឲ្យមោហោចូលផ្សាលផ្សាញ់ ។
ស្រោះស្រួលរមួលមាត់ពីគ្រោះគ្នា   បុត្រីបុត្រាជាសម្លាញ់
លះបង់ទ្រព្យធនកាត់កំណាញ់   សាងផលកញ្ញាញ់យកនិព្វាន ។
មួយគឺខ្ញុំបានស្ថាបនា   អាគារសិក្សាជាវិមាន
សាលាជាន់ខ្ពស់សម្រាប់រៀន   មធ្យមក្មេងក្បួនវិជ្ជាខ្ពស់ ។
ប្រគេនថ្វាយសង្ឃចូលរៀនសូត្រ   បាលីរហូតភាសាអស់
សង្ឃក្រឹតជាដើមជារបស់   វិជ្ជាសប្បុរសពុទ្ធសាសនា ។
នៅនាអារាមវត្តពោធិវាល   ជាទីកណ្តាលដែនកម្ពុជា
ខេត្តស្រុកបាត់ដំបងជាមួយគ្នា   សម្រាប់ពុះពារក្តីល្ងង់ខ្លៅ ។
តាំងតាមបែបសម័យនិយម   គួរឲ្យអភិរម្យជាប់ជួននៅ
ស្ថាបនាលំអរទាំងក្នុងក្រៅ   ជាប់តកូនចៅទៅថ្ងៃក្រោយ ។
ពីរគឺមន្ទីរពេទ្យពីរល្វែង   សម្រាប់ចាត់ចែងជាអំណោយ

ព្យាបាលរោគសង្ឃកុំបួស់ឆ្ងាយ ប្រយោជន៍នឹងឲ្យសុខស្រួល-
កាយ ។ បីបុស្បបុកដាក់អង្គព្រះដី សាងទុកក្នុងទីធំទូលាយ
មហាវិហារយ៉ាងល្អគួររីករាយ ប្រជុំសប្បាយវត្តពោធិវាល ។
បួនគឺពុទ្ធបាទលោហធាតុ សម្រាប់អភិវាទល្អត្រកាល
ជាទីគោរពយ៉ាងស្និតស្នាល ប្រណាម្យឱនក្បាលដៃឆ្វេងស្តាំ ។
ប្រាំកុដិសមាធិសម្រាប់សង្ឃ មិនចំពោះអង្គគង់បរិកម្ម
ភាវនាកម្មដ្ឋាននៅប្រចាំ ពីរខ្នងឆ្វេងស្តាំផ្លាយយកសុខ ។
ប្រាំមួយបន្ទប់កសិណវត្តកណ្តាល នឹងវត្តពោធិវាលសម្រាប់ទុក
ជូនលោកយាយតាពុំរើសមុខ ស្មឹងស្មាធ៍យកសុខពិតប្រាកដ ។
ប្រាំពីរសាងសាលាបាលី ទឹងបួលសាងទីឧបោសថ
ក្នុងបុប្ផារាមដែលជាវត្ត មាននាមប្រាកដល្បីជាក់ស្តែង ។
ប្រាំបីបានបួលសាងវិហារ ថ្វាយព្រះឈ្មោះមារវត្តកំផែង
ប្រាំបួនវត្តពោធិវាលនេះឯង បួលជួយចាត់ចែងសាងវិហារ ។
ដប់បានបួលសាងអង្គព្រះដី ឲ្យជនប្រុសស្រីនមស្សការ
មួយនៅវត្តគរក្នុងវិហារ មួយទៀតនៅនាវត្តបឹងរាំង ។

ដប់មួយបានចូលសាងវិហារ   នៅវត្តបាក់ព្រាយយ៉ាងសម្រាំង
ដប់ពីរសាងព្រះដីទាំងបល័ង្គ   ដំកល់តាំងនៅវត្តជ្រោយស្ដៅ ។
ដប់បីចូលដងត្តានឹងជ្វា   សាងនៅនាវត្តភ្នំសម្ពៅ
ដប់បួនបានបបួលកូនចៅ   ចូលសមាជិកនៅពេទ្យព្រះសង្ឃ។
បានចូលកសាងបានឧបត្ថម្ភ   បង់ថ្លៃរាល់ឆ្នាំឥតឲ្យហ្មង
ពុំដែលមានខានខែណាម្ដង   ដោយចិត្តបំណងយកក្ដីសុខ ។
ដប់ប្រាំបានចូលសាងវិហារ   ឧណ្ណាលោមភ្នំពេញបតុមុខ
ដប់ប្រាំមួយ បានសាងព្រះបាទទុក ព្រះធីបុស្សបុកវត្តពោធិវាល។
ដប់ប្រាំពីរសាងព្រះបាទទាំងគូ   នឹងអង្គបរមគ្រូត្រកាល
ដាក់វត្តក្រឡាញ់ដោយបណ្ដាល ចិត្តនឹកដល់កាលជាតិដំបន់ ។
ដប់ប្រាំបីសាងរូបព្រះនិព្វាន   ដប់ប្រាំបួនបានសាងរូបព្រះអានន្ទ
ម្ភៃសាងពុទ្ធដិកាព្រះភគវន្ត   ប្រាំបីម៉ឺនបួនពាន់ព្រះធម្មខន្ធ ។
បុណ្យទានសីលនឹងភាវនា   នេះជាបាគាបច្ចុប្បន្ន
អនុស្សតិកម្មដ្ឋានព្រះអរហន្ត   ទុកកុំឲ្យភាន់ភាំងស្មារតី ។
ខ្ញុំតាមសៀវ-ភៅមេគ្រួសា   នឹងបុត្តធីតាទាំងប្រុសស្រី

កូនខ្ញុំអ៊ុំង-ម៉ារីយ៉ានក្តី  អ៊ាប-លាង ហ៊ា-ស្រី អ៊ុំង-ស្មៀង ។
អ៊ុំង-ហ៊ាំង,អ៊ុំង-ស្មៀនទាំងអស់ឯង បានជួយចាត់ចែងចិត្តគិត
ស្មៀង ជឿព្រះសាសនាឥតជ្រែជ្រៀង ទៀងតាមពូជពង្សវង្សត្រកូ-
ល ។ សូមតេជះគុណបុណ្យទ្រទ្រង់ ពូជពង្សវង្សខ្ញុំទាំងអស់គ្នា
កុំឲ្យវាតឃាតចិត្ត  ពីព្រះសាសនាព្រះអង្គឡើយ ។
ខ្ញុំសូមប្រាថ្នាព្រះនិព្វាន  ដោយសតិញ្ញាណពុំកន្តើយ
សូមបានសម្រេចមគ្គផលហើយ ព្រះត្រាស់ជាន់ក្រោយត្រានោះ
ឯង ។ ហើយខ្ញុំសូមផ្តង់ដួងចិត្ត ជូនភាគផលខ្ញុំចាត់ចែង
ដល់លោកមានគុណលើខ្ញុំឯង ផ្សាយបេញជូនស្តែងដល់
គ្រួសា ។

លោកបំរើនសម្បត្តិនាម អ៊ុំង-ធូង ជាដួងបេះដូងដែលមរណា
សូមលោកទទួលយកផលា ហើយសោយសុខាជាដើមផង ។
សូមថ្វាយកុសលដ៏ប្រណិត ឆ្ពោះព្រះទសពិធក្សត្រគ្រប់គ្រង
ប្រទេសកម្ពុជាយើងនេះផង បានដូចបំណងព្រះហឫទ័យ ។
ថ្វាយឆ្ពោះសម្តេចព្រះបិតា  ប្រមុខរដ្ឋាមានជោគជ័យ

សូមទ្រង់ប្រាស់បាកទុក្ខរោគភ័យ បានជួបព្រះទ័យប៉ងប្រាថ្នា ។
សូមឲ្យព្រះអង្គមានព្រះជន្ម រាប់រយវស្សន្តកុបសុខា
គង់ជាម្លប់ជាតិកម្ពុជា សាងជាតិសាសនារាជបល័ង្ក ។
សូមអស់ព្រះវង្សពង្សក្សត្រា ទាំងអ្នករាជការបិត្តជួបស័ង្ខ
សស្អាតស្រទព្វាញរាជបល្ល័ង្ក បានសុខសម្រាំងប្រសើរហោង។

បត្តិទានគាថា ប្រែបទបប្បរិត

យេកេចិខុទ្ទកាបាណា មហន្តាបិមយាហតា
យេបាណោកេបមានេន កាយវាចាមនេហិវា
បុញ្ញំមេអនុមោទន្តុ គណ្ហន្តុផលមុត្តមំ
វេរំនោចេបមុញ្ចន្តុ សព្វទោសំខមន្តុមេ

សត្វមានជីវិតទាំងឡាយឯណា ដែលមានកាយាតូចក្តីធំក្តី
ក្រែងខ្ញុំសម្លាប់ដោយភ្លាត់ស្មារតី កាយឬវាចីចិត្តខ្ញុំពាធា ។
សូមសត្វទាំងនោះអនុមោទនា យកបុណ្យថ្លៃថ្លាភាគផលឧត្តម
ហើយបួរលែងពៀរវេរាពីខ្ញុំ សូមសត្វនោះកុំប្រកាន់ទោសឡើយ

ផ្សាយមេត្តាដោយ

ឧបាសិកា សៀវ-ថៅ

នមស្សការ ប្រែបទបព្យាវត

**នមោឱមាត្យារទ្ធស្ស    រតនត្តយស្សសាធុកំ**

សូមថ្វាយបង្គំប្រជុំត្រ័យរ័ត្ន    ប្រារព្ធដោយបទម្នាន ៣ ប្រការ

ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យប្រឹងប្លែងពុំបាន។

**នមោការស្សតេជេន    វិធិម្ហិ ហោមិ តេជវា**

សូមថ្វាយបង្គំត្រ័យរ័ត្នសោភា    តេជះបេស្ដាប្ចូរមានដល់ខ្ញុំ

ក្នុងពិធីធ្វើកិច្ចថ្វាយបង្គំ    តេជះបុណ្យធំសូមកើតមានឡើង។

កាយបូជា ប្រែបទបព្យាវត

**សីសំមេបទុមំកត្វា    ទីបញ្ហានយនទ្វយំ**

**វចសាធូបការេន    មនសា ចតុគន្ធកា**

សីសះនៃខ្ញុំធ្វើជាបទុមជាតិ    នេត្រពីរល្អស្អាតជាប្រទីបថ្វាលា

ពាក្យពោលធម៌ពិតជាធូបបូជា    ចិត្តដែលជ្រះថ្លាជាបតុគន្ធរស ។

បូជាព្រះពុទ្ធព្រះធម៌ព្រះសង្ឃ    ដោយចិត្តស្មោះត្រង់ត្រ័យរ័ត្ន

ជាន់ខ្ពស់

សូមបានត្រាស់ដឹងនូវធម្មរស ប្រសើរខ្ពង់ខ្ពស់ក្នុងនិព្វានហោង។

បទកាកគតិ

នាមខ្ញុំតួ ញ.    ស្រះតិខ្យល់ ម.    បង្គំនឹកគុណ

ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន សូមតេជបុណ្យ
មកជួយទ្រទ្រង់។ ឲ្យមានបញ្ញា ភ្លឺថ្លាស់ជ្រះថ្លា
ដូចខែពេញវង់ ឥតមានពពក បិទបាំងភ្លឺយង់
ទំនឹងតែងពង្ស ពុទ្ធភាសិតំ ។ ធម្មមន្ដ
មានក្នុងគម្ពីរ តេបិដកំ ជាពាក្យភាសិត
សម្រិតសម្រាំង តាមដោយកម្លាំង សតិញាណហោង។

ធម្មិស្សរោ

១ ឧបនេយ្យសូត្រ ប្រែបទព្រហ្មគីត
ទេវតាភាសិត ១–

ឧបនីយតិជី– វិតមប្បមាយុំ
ជរូបនីតស្ស នសន្តិ តាណា
ឯតំ ភយំម– ទរណេ បេក្ខមានោ
បុញ្ញានិកយិរាថ– សុខាវហានិ ។

អាយុសត្វទាំងឡាយ រស់នៅសព្វាយតិចពេកណាស់
ជរានាំឲ្យចាស់ ទាញឆាប់ណាស់ទៅរកស្លាប់។
កាលសត្វត្រូវជរា ស្លាប់ពាធាស្លុះប្រញាប់
រកទីពឹងផុតស្លាប់ ការបំណាច់ពុំរួចឡើយ ។

បើជនឃើញភ័យនោះ ក្នុងស្លាប់ស្មោះប្រាកដហើយៈ
ធ្វើបុណ្យកុំកន្តើយ ជាគុណឲ្យបានក្តីសុខ ។

ពុទ្ធភាសិត ២

ឧបនីយតិជី- វិតមប្បមាយុំ
ជរូបនីតស្ស- ន សន្តិ តាណា
ឯតំ ភយំ ម- រណេ បេក្ខមានោ
លោកាមិសំ ប- ជហេ សន្តិបេក្ខោ ។

អាយុសត្វទាំងឡាយ រស់នៅសប្បាយតិចពេកណាស់
ជរានាំឲ្យចាស់ ទាញឆាប់ណាស់ទៅរកស្លាប់ ។
កាលសត្វត្រូវជរា ស្លាប់ពាធាស្ទុះប្រញាប់
រកទីពឹងផុតស្លាប់ ការបំណាប់ពុំរួចឡើយ ។
បើជនឃើញភ័យនោះ ក្នុងស្លាប់ស្មោះប្រាកដហើយ
ត្រូវស្ងប់កុំកន្តើយ លះអាមិសក្នុងលោកបេញ ។

៦ អព្ភេន្តិសូត្រ ប្រែបទព្រហ្មគីត

ទេវតាភាសិត ៣-

កាលពេលតែងកន្លង រាត្រីធ្លងផុតហួសទៅ
ជុំនាន់វ័យមិនតាំងនៅ តែងលះទៅជាលុំដាប់ ។

កាលបើបានឃើញភ័យ    ក្នុងក្តីស្លាប់ហើយប្រញាប់
ធ្វើបុណ្យល្អបំណាប់    នាំសុខគាប់មកដល់ខ្លួន ។

ពុទ្ធភាសិត ៤ -

**អច្ចេន្តិកាលា    តរយន្តិ    រត្តិយោ**
**វយោគុណា    អនុបុព្វំ    ជហន្តិ**
**ឯតភយំ    មរណោ    បេក្ខមានោ**
**លោកាមិសំ    បជហេ    សន្តិបេក្ខោ ។**

កាលពេលតែងកន្លង    រាត្រីយឆ្លងផុតហួសទៅ
ជំទាន់វ័យមិនតាំងនៅ    តែងលះទៅជាលំដាប់ ។
កាលបើបានឃើញភ័យ    ក្នុងក្តីស្លាប់ហើយប្រញាប់
យកក្តីស្ងប់ល្អគាប់    លះអាមិសក្នុងលោកចេញ ។

៣ – គតិច្ឆិន្ទិសូត្រ    ប្រែបទបញ្ញាវត

ទេវតាភាសិត ៥ -

ជនត្រូវកាត់បង់នូវធម៌ប៉ុន្មាន    ត្រូវលះឲ្យបានធម៌ប៉ុន្មានទៅ
ត្រូវចំរើនធម៌ប៉ុន្មានហើយនៅ    លះជាប់អ្វីហៅឆ្លងឱឃៈបាន ។

ពុទ្ធភាសិត ៦

**បញ្ចឆិន្ទេបញ្ចជហេ    បញ្ចុត្តរិភាវយេ**

បញ្ចសង្ខាតិគោតិក្ក ឱឃតិណ្ណោតិវុច្ចតិ ។

ជនត្រូវកាត់ផ្តាច់សំយោជនៈ ខាងក្រោម[១]ប្រាំថ្នាក់លះខាងលើ[២]ប្រាំ

បំរើនឥន្ទ្រីយ[៣]ទាំងប្រាំមុតមាំ លះជំពាក់[៤]ប្រាំឆ្លងឱឃៈបាន។

៤– ជាគរសូត្រ ប្រែបទបប្បវត

ទេវតាភាសិត៧–

ធម៌គ្រឿងដេកលក់អ្នកកំពុងភ្ញាក់, មានប៉ុន្មានថ្នាក់ធ្វើឲ្យលក់បាទ
ធម៌ជាគ្រឿងភ្ញាក់អ្នកដេកសម្រាន មានប៉ុន្មានស្ពានធ្វើជនឲ្យ-ភ្ញាក់ ។

ធុលីកិលេសធម៌មានប៉ុន្មាន ធ្វើជនឲ្យមានចិត្តជាប់ប្រឡាក់
ជនស្អាតព្រោះធម៌អ្វីគ្មានជំពាក់ មានប៉ុន្មានថ្នាក់ធ្វើជនឲ្យស្អាត។

ពុទ្ធភាសិត ៨–

បញ្ចជាគរតំសុត្តា បញ្ចសុត្តេសុជាគរា
បញ្ចភិរជមាទេតិ បញ្ចភិ បរិសុជ្ឈតិ

---

(១) សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាស, កាមឆន្ទៈ ព្យាបាទៈ ។

(២) រូបរាគៈ, អរូបរាគ, មានៈ, ឧទ្ធច្ចៈ, អវិជ្ជា ។

(៣) សទ្ធិន្ទ្រីយ, វិរិយិន្ទ្រីយ, សតិន្ទ្រីយ, សមាធិន្ទ្រីយ, បញ្ញិន្ទ្រីយ ។

(៤) រាគសង្គៈ, ទោសសង្គៈ, មោហសង្គៈ, មានសង្គៈ, ទិដ្ឋិសង្គៈ ។

នីវរណៈ(១) ប្រាំជាគ្រឿងនាំលក់ អ្នកមិនទ្រមក់ធ្វើឲ្យលក់បាន
ឥន្ទ្រីយ(២) ទាំងប្រាំគ្រឿងភ្ញាក់ចាកសភាន អ្នកមានសន្តានកំពុង-
ដេកលក់ ។

ជនតែងប្រទូស្តក់ដោយធម៌លាមក ធុលីឬភក់នីវរណៈប្រាំ
តែងស្អាតព្រោះឥន្ទ្រីយប្រាំមុតមាំ គឺឥន្ទ្រីយប្រាំដែលបរិសុទ្ធ-
ហើយ ។

៥ - អប្បដិវិទិសូត្រ ប្រែបទចប្បវត

ទេវតាភាសិត ៩-

ជនណាមិនទាន់យល់ធម៌ច្បាស់ទេ, ជននោះតែងវង្វេងលទ្ធិក្រៅ
ទុកជាកាលគួរជននោះភ្ញាក់ទៅ ជននោះក៏នៅតែដេកមិនភ្ញាក់ ។

ពុទ្ធភាសិត ១០-

**យេសំធម្មាសុប្បដិវិទិតា បរវាទេសុ ន នីយរេ**
**សម្ពុទ្ធាសម្មទញ្ញាយ ចរន្តិវិសមេសមំ ។**

ជនណាដែលបានយល់ធម៌ច្បាស់ល្អ ជននោះបរិមិនជឿលទ្ធិ-
ក្រៅ

(១) កាមច្ឆន្ទៈ, ព្យាបាទៈ, ថីនមិទ្ធៈ, ឧទ្ធច្ចកុក្កុច្ចៈ, វិចិកិច្ឆា ។
(២) សទ្ធិន្ទ្រិយ, វីរិន្ទ្រិយ, សតិន្ទ្រិយ, សមាធិន្ទ្រិយ, បញ្ញិន្ទ្រិយ ។

ជននោះឈ្មោះថាភ្ញាក់ខ្លួនឯងទៅ ឈ្មោះថាយល់ជ្រៅដឹងធម៌

តាមគន់ ។

រមែងប្រព្រឹត្តធម៌ស្មើមិនអន់ ក្នុងលោកសន្និវាសមិនស្មើ ។

៦- សុសម្មុដ្ឋសូត្រ ប្រែបទបង្សាវត

ទេវតាភាសិត ១១ -

ពួកជនណាភាន់ប្រទ្បូធម៌ពិត ជននោះប្រព្រឹត្តជឿលទ្ធិក្រៅ

ទុកជាកាលគួរជននោះភ្ញាក់ទៅ ជននោះក៏នៅតែដេកមិនភ្ញាក់ ។

ពុទ្ធភាសិត ១២ -

**យេសំធម្មា អសម្មុដ្ឋា បរវាទេសុ ន នីយរេ**

**សម្ពុទ្ធាសម្មទញ្ញាយ ចរន្តិវិសមេ សមំ ។**

ជនណាមិនភាន់ប្រទ្បូធម៌ពិត នោះមិនប្រព្រឹត្តជឿលទ្ធិក្រៅ

ជននោះឈ្មោះថាភ្ញាក់ខ្លួនឯងទៅ ឈ្មោះថាយល់ជ្រៅត្រាស់ដឹង

តាមគន់ ។

រមែងប្រព្រឹត្តធម៌ស្មើមិនអន់ ក្នុងលោកសន្និវាសមិនស្មើ ។

៧-មានកាមសូត្រ ប្រែបទព្រហ្មគីត

ទេវតាភាសិត ១៣-

---

មាន៖បហាយ សុសមាហិតត្តោ

សុចេតសោសព្វ– ធិវិប្បមុត្តោ
ឯកោអរញ្ញេ វិហរំអប្បមត្តោ
ស មច្ចុធេយ្យ ស្ស– តរេយ្យបារំ ។

អ្នកព្រះមានះបាន តាំងសន្តានចិត្តប្រពៃ
ឧបហារសមាធិថ្លៃ ចិត្តផូរផង់ល្អត្រចះ ។
បាកធម៌គ្រឿងសៅហ្មង ទាំងអស់ផង់ផុតស្រឡះ
ម្នាក់ឯងព្រៃជាផ្ទះ ព្រះស្រឡះឥតសល់ឡើយ ។
អ្នកនោះនឹងបានឆ្លង វិដ្តសង្សារមានត្រើយ
កាត់បំណងមច្ចុហើយ ឆ្លងដល់ត្រើយនិព្វានហោង ។

៨– អរញ្ញសូត្រ ប្រែបទបប្បាវត

ទេវតាភាសិត១៤–

ព្រហ្មចារីភិក្ខុដែលនៅក្នុងព្រៃ ស្ងួតស្ងប់ប្រពៃរម្ងាប់ចិត្តបាន ឆាន់បាយតែម្តងពណ៌កាយកល្យាណ នៅផូរផង់បានតើដោយហេតុអ្វី ។

ពុទ្ធភាសិត ១៥–

អតីតំនានុសោចន្តិ នប្បជប្បន្តិនាគតំ
បច្ចុប្បន្នេន យាបេន្តិ តេនវណ្ណោបសីទតិ

អនាគតប្បជប្បាយ អតីតស្សានុសោចនា
ឯតេនពាលាសុស្សន្តិ នឡោវហរិតោលុតោ ។

ភិក្ខុនោះមិនមានចិត្តសោកស្តាយ របស់ទាំងឡាយកន្លងទៅ
ហើយ

គ្មានប្រាថ្នាទ្រព្យមិនទាន់មកឡើយ រស់នៅស្រួលហើយដោយ
ទ្រព្យបច្ចុប្បន្ន ។

បានជាពណ៌កាយផូរផង់មិនអន់ ពួកពាលរយពាន់តែងស្រ-
ពោននៅ

ដោយហេតុទាំងពីរនេះនាំឲ្យក្តៅ, ព្រោះប្រាថ្នាទៅរកទ្រព្យពុំមាន។

ព្រោះស្តាយរបស់កន្លងបាកស្មាន ដូចបបុះមានដើមពណ៌ខៀវ-
ស្រស់

ដែលត្រូវគេប្រូតដើមហោលទាំងអស់ ក៏ក្រៀមក្រញស់ដូច-
ពាលនោះឯង ។

៩ – នន្ទិសូត្រ ប្រែបទបហ្សាវត

ទេវតាភាសិត១៦ –

អ្នកមានកូនតែងអរនឹងកូនពិត អ្នកមានគោចិត្តអរនឹងគោគេ

ឧបធិកិលេសទាំងឡាយជាអេ ញាំងចិត្តយើងគេឲ្យអរទូទៅ ។
អ្នកណាដែលគ្មានឧបធិមិនក្តៅ អ្នកនោះលោកហៅថាគ្មាន-
ត្រេកអរ ។

ពុទ្ធភាសិត ១៧-

**សោចតិ បុត្តេហិ បុត្តិមា គោមិកោ គោហិ តថេវ សោចតិ**
**ឧបធីហិ នរស្ស សោចនា នហិ សោ សោចតិ យោ និរូបធិ**

អ្នកមានកូនតែងសោកនឹងកូនពិត អ្នកមានគោចិត្តសោកស្តាយ
គោគេ
ដ្បិតធម៌ឧបធិ [១] ទាំងឡាយជាមេ ញាំងចិត្តយើងគេឲ្យសោយ-
សោកបាន ។
លុះតែអ្នកណាឧបធិមិនមាន អ្នកនោះទើបបានមិនសោយ-
សោកឡើយ ។

១០ នត្ថិបុត្តសមសូត្រ ប្រែប ទចប្បវត

ទេវតាភាសិត ១៨-

សេចក្តីស្រឡាញ់ស្មើកូនមិនមាន ខាងឯធនធានគ្មានស្មើគោ
ឡើយ

(១) ឧបធិ ៤ យ៉ាងគឺ កាមូបធិ ១ ខន្ធូបធិ ១ កិលេសូបធិ ១ អភិសង្ខារូបធិ ១

ពន្លឺព្រះអាទិត្យដែលរះឡើងហើយ គ្មានអ្វីស្មើឡើយក្នុងលោក-ភ្លឺផុត ។

បណ្ដាស្រះទឹកមានតែស្រមុទ្រ នោះទើបធំផុតជាងគេក្នុងលោក។

ពុទ្ធភាសិត ១៩-

នត្ថិ អត្តសមំ បេមំ នត្ថិ ធញ្ញសមំ ធនំ
នត្ថិ បញ្ញាសមា អាភា វុដ្ឋិ វេ បរមា សរា ។

សេចក្ដីស្រឡាញ់ស្មើខ្លួនមិនមាន ខាងឯធនធានគ្មានអ្វីស្មើស្រូវ ភ្លឺអ្វីពុំស្មើបញ្ញាយល់ត្រូវ ទឹកភ្លៀងធ្វើស្រូវជាស្រះធំផុត ។

១១- ខត្តិយសូត្រ ប្រៀបទេបប្បរិត

ទេវតាភាសិត២១-

ជាតិក្សត្រប្រសើរជាងសត្វជើងពីរ, គោឬក្របីលើសសត្វជើងបួន ប្រពន្ធក្មេងល្អជាងស្រីចាស់ខ្លួន, កូនច្បងតាមក្បួនប្រសើរជាងគេ

ពុទ្ធភាសិត ២១-

សម្ពុទ្ធោ ទិបទំ សេដ្ឋោ អាជានីយោ ចតុប្បទំ
សុស្សូសា សេដ្ឋា ភរិយានំ យោ ច បុត្តានមស្សវោ ។

ព្រះពុទ្ធប្រសើរជាងសត្វជើងពីរ អាជានេយ្យពិសីលើសសត្វ-ជើងបួន

ប្រពន្ធស្ដាប់ប្ដីប្រសើរមាំមួន កូនស្ដាប់ពាក្យឪពុកប្រសើរមែន-
ហោង ។

១២- ហិរិសូត្រ ប្រែថាខ្មាសបាប

ទេវតាភាសិត ២២-

បុរសលះបង់អំពើរអាក្រក់,សម្លាប់ឬបកដោយខ្មាស់អៀនបាន
នោះរកបានតិចក្នុងលោកក្រមាន បុរសកល្យាណយ៉ាងនោះ-
តិចណាស់ ។

ដូចជាសេះល្អគក់ស្គាល់នឹងម្ចាស់ នោះក្រពេកណាស់ដែលមាន-
ក្នុងលោក ។

ពុទ្ធភាសិត ២៣-

**ហិរិនិសេធោ តនុយា យេចរន្តិសទាសតា**
**អន្តំទុក្ខស្សបប្បុយ្យ ចរន្តិវិសមេសមំ** ។

ពួកជនដែលមានសតិរាល់វេលា ប្រព្រឹត្តការពារអាក្រក់រករាន
ដោយក្ដីអៀនខ្មាស់ឲ្យបានគ្រប់ប្រាណ នោះសឹងរកគ្មានដល់មាក់-
សោះឡើយ ។

លុះតែជនបានផងស្ពានដល់ត្រើយ ទីផុតទុក្ខហើយប្រព្រឹត្ត-
ធម៌ស្មើរ ។

ក្នុងលោកសន្និវាសប្រសើរ ដែលមិនមានស្មើរធ្វើឲ្យស្មើរបាន ។

១៣ – កុដិកាសូត្រ ប្រែបទបញ្ហាវត

ទេវតាភាសិត ២៤–

ខ្ញុំមនៃព្រះអង្គមិនមានឬទេ សម្បកដូចគេគ្មានទេឬអ្វី
ដំណាវង្សទ្រទង់ក៏គ្មានដែរឥ ព្រះអង្គរួចពីចំណងហើយឬ ។

ពុទ្ធភាសិត ២៥–

**តគ្ឃមេកុដិកានត្ថិ តគ្ឃនត្ថិកុលាវកា**
**តគ្ឃសន្តានកានត្ថិ តគ្ឃមុត្តោម្ហិ ពន្ធនា**

ខ្ញុំមនៃតថាគតគ្មានសោះទេ សម្បកដូចគេក៏គ្មានសោះដែរ
ដំណាវង្សទៀតក៏ផុតក្រសែ តថាគតរួចខ្សែចងប្រាកដហើយ ។

ទេវតាភាសិត២៦–

ខ្ញុំពោលដៅអ្វីថាខ្ញុំមព្រះអង្គ ខ្ញុំពោលផ្ទុំដអ្វីជាសម្បក
ខ្ញុំពោលដៅអ្វីតវង្សទៅមុខ ខ្ញុំពោលដៅទុកអ្វីចងព្រះអង្គ ។

ពុទ្ធភាសិត ២៧–

អ្នកថាមាតាទុកដូចជាខ្ញុំម អ្នកថាភាណបម(១)ទុកជាសម្បក
អ្នកពោលថាបុត្រតវង្សទៅមុខ ថាតណ្ហាទុកជាចំណងប្រាណ ។

(១) ប្រពន្ធដើម គឺប្រពន្ធទី១ ប្រពន្ធមានខាន់ស្លា មានចុះលិខិតផ្គ្នា(អេតាស៊ីវិល)

ទេវតាភាសិត ២៨

ព្រះអង្គគ្មានទុក្ខគ្មានទាំងសម្បុក គ្មានតរឹង្សទុកទៅមុខទៀត-
ឡើយ

ព្រះអង្គប្រាសចាកចំណងមែនហើយ ទ្រង់ឆ្លងផុតត្រើយនិព្វាន-
ស្រួលហោង ។

១៨- កិន្ទទសូត្រ ប្រែបទបព្យាវត

ទេវតាភាសិត ២៩-

ជនឲ្យអ្វីឈ្មោះថាឲ្យកម្លាំង ឲ្យអ្វីសម្រាំងឈ្មោះថាឲ្យពណ៌មុខ
ឲ្យអ្វីឈ្មោះថាឲ្យសេចក្ដីសុខ ឲ្យអ្វីលោកទុកថាឲ្យទានភ្នែក ។
ជនណាឲ្យអ្វីហៅឲ្យគ្រប់បែបច ឲ្យនេះបំផ្លែកឈ្មោះថាឲ្យអ្វី
ខ្ញុំសូមព្រះអង្គទ្រង់នាមជិនស្រី មេត្តាប្រណីប្រាប់ខ្ញុំឲ្យទាន ។

ពុទ្ធភាសិត ៣០-

**អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ**
**យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ ។**
**សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ**
**អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ**

ឲ្យបាយឈ្មោះថាឲ្យកម្លាំងកាយ ឲ្យសំពត់ទាំងឡាយហៅថា-
ឲ្យពណ៌មុខ

ឲ្យយានជំនិះហៅឲ្យក្ដីសុខ ឲ្យប្រទីបទុកដូចជាឲ្យភ្នែក ។
អ្នកឲ្យទីនៅអាស្រ័យផ្ទែក ៗ ឈ្មោះថាឲ្យប៉ែករបស់គ្រប់យ៉ាង
អ្នកប្រដៅធម៌នាំគេកសាង ទានសីលគ្រប់យ៉ាងហៅឲ្យនិព្វាន ៗ

១៥– វនរោបសូត្រ ប្រែបទបព្វាវត

ទេវតាភាសិត ៣១–

បុណ្យតែងចំរើនទាំងថ្ងៃទាំងយប់ ហូរមកមិនឈប់គ្រប់ៗវេលា
ដល់ជនពួកណាអ្នកមានសទ្ធា នឹងជនឈ្មោះថាតាំងនៅក្នុងធម៌
ឈ្មោះថាបរិបូណ៌ដោយសីលបវរ, ទៅកាន់ទីល្អគឺស្ថានសួរបាន ៗ

ពុទ្ធភាសិត ៣២–

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

ជនណាដាំសួនឈើមានផ្កាផ្លែ, ដាំសួនសុទ្ធតែឈើដែលមានម្លប់
សាងស្ពានសាងរោងទុកឲ្យគេឈប់ ឲ្យទានទឹកគ្រប់ជីកអណ្ដូង
ស្រះ ៗ

ជនណាឲ្យទីនៅអាស្រ័យ ៗនុះ បុណ្យតែងកើតបះទាំងថ្ងៃទាំង-
យប់

កើតរាល់វេលាមិនដាច់គ្មានឈប់ បុណ្យហូរមកគ្រប់ដល់ជន-
នោះឯង ។

ជននោះឈ្មោះថាអ្នកបេះបាត់បែង បេះតាំងៗនឯងស្ថិតនៅក្នុង
ធម៌

ឈ្មោះថាបរិបូណ៌ដោយសីលបវរ,ទៅកាន់ទីល្អគឺស្ថានសួរបាន។

១៦ – ជរាសូត្រ ប្រែបទបញ្ញារត

ទេវតាភាសិត ៣៣—

អ្វីហ្ន៎ជាគុណអាចញ៉ាំងប្រយោជន៍ ច្រើនតិចដោយហេតុបឲ្យ-
សំរេចបាន

ជរាបងល់ចាស់ជរាគ្រប់ប្រាណ អ្វីបុគ្គលបានដំកល់ទុកហើយ។

អាចញ៉ាំងប្រយោជន៍ជនឲ្យដល់ត្រើយ យ៉ាងធំពេកឡើយឲ្យ-
សំរេចបាន

អ្វីជាដួងកែវនៃជនគ្រប់ប្រាណ អ្វីចោរមិនមានលួចយកបាន-
ឡើយ ។

ពុទ្ធភាសិត ៣៤-

សីលំយាវជរាសាធុ សទ្ធាសាធុបតិដ្ឋិតា
បញ្ញានរានំរតនំ បុញ្ញំចោរេហិទូហរំ ។

សីលជាគុណជាតិអាចញ៉ាំងប្រយោជន៍ ច្រើនតិចដោយហោច-ឡើងសំរេចបាន

ដរាបដល់ចាស់ជរាគ្រប់ប្រាណ, សទ្ធាជនបានដំកល់ទុកហើយ។

អាចញ៉ាំងប្រយោជន៍ជនឲ្យដល់ត្រើយ យ៉ាងធំពេកឡើយឲ្យ-សំរេចបាន

បញ្ញាជាដួងកែវជនគ្រប់ប្រាណ បុណ្យចោរមិនមានលួចយក-បានឡើយ ។

១៧- មិត្តសូត្រ ប្រែបទបប្បរិត

ទេវតាភាសិត ៣៥-

អ្វីហ្ន៎ជាមិត្តអ្នកដើរផ្លូវទៅ អ្វីជាមិត្តនៅក្នុងផ្ទះនៃខ្លួន
អ្វីមិត្តកាលមានធុរៈមាំមួន អ្វីមិត្តតាមខ្លួនទៅក្នុងភពមុខ។

ពុទ្ធភាសិត ៣៦-

សត្ថោបសវតោមិត្តំ មាតាមិត្តំសកេឃរេ
សហាយោអត្ថជាតស្ស ហោតិមិត្តំបុនប្បុនំ

**សយំកតានិបុញ្ញានិ តំមិត្តំសម្បរាយិកំ ។**

បក្ខពួកជាមិត្តអ្នកដើរផ្លូវទៅ មាតាមិត្តនៅក្នុងផ្ទះនៃខ្លួន
អ្នកមានចិត្តស្មើរជាមិត្តមាំមួន កាលធុរៈខ្លួនកើតឡើងម្តង ៗ ។
បុណ្យខ្លួនធ្វើហើយជាមិត្តខ្លួនផង ទៅតាមបំណងខ្លួនក្នុង–
ភពមុខ ។

### ១៨– វត្ថុសូត្រ ប្រែបទជរាវគ

ទេវតាភាសិត ៣៧–

អ្វីជាពំនាក់នៃមនុស្សគ្រប់គ្នា អ្វីក្រៅដែលជាសម្លាញ់ប្រសើរ
សត្វអាងជីវិតក្នុងលោកនេះតើ រស់នៅទៅស្មើរអាស្រ័យនឹងអ្វី ។

ពុទ្ធភាសិត ៣៨–

**បុត្តវត្ថុមនុស្សានំ ភរិយាបរមាសខា**
**វុដ្ឋិភូតា ឧបជីវន្តិ យេបាណាបឋវីសិតា ។**

កូនជាពំនាក់នៃមនុស្សគ្រប់គ្នា ឯភរិយាជាសម្លាញ់ប្រសើរ
សត្វមានជីវិតក្នុងលោករស់ស្មើ រស់នៅប្រសើរអាស្រ័យទឹក
ភ្លៀង ។

១៩-បឋមជនសូត្រ ប្រែបទបព្វាវិត

ទេវតាភាសិត៣៩-

អ្វីហ្ន៎តែងញ៉ាំងបុរសឲ្យកើត អ្វីរបស់ផើតប្រុសតែងស្ទុះស្ទារ
អ្វីតែងអន្ទោលទៅក្នុងសង្សារ អ្វីជាមហាភ័យរបស់សត្វ ។

ពុទ្ធភាសិត ៤០-

តណ្ហា ជនេតិ បុរិសំ ចិត្តមស្ស វិធាវតិ
សត្តោ សំសារមាបាទិ ទុក្ខមស្ស មហព្ភយំ ។

តណ្ហាតែងញ៉ាំងបុរសឲ្យកើត ចិត្តបុរសផើតនោះតែងស្ទុះស្ទារ
សត្វតែងអន្ទោលទៅក្នុងសង្សារ ទុក្ខព្រួយជាមហាភ័យរបស់-
សត្វ ។

២០-ទុតិយសូត្រ ប្រែបទបព្វាវិត

ទេវតាភាសិត ៤១-

អ្វីជាទីពឹងរបស់បុរស អ្វីជារបស់គ្រងបុរសនោះ
សត្វដែលត្រេកអរនឹងធម៌អ្វីស្មោះ ទើបរួចទុក្ខនោះទាំងអស់ទៅ-
បាន ។

ពុទ្ធភាសិត ៤២-

សទ្ធា ទុតិយា បុរិសស្ស ហោតិ បញ្ញា ចេនំ បសាសតិ

និព្វានាតិរគោបរេច្ចា សព្វទុក្ខា បមុច្ចតិ ។

សទ្ធាជាទីពីរនៃបុរស បញ្ញាជារបស់គ្រងបុរសនោះ សត្វត្រេកអរនឹងនិព្វានធម៌ស្មោះ ទើបរួចទុក្ខនោះទាំងអស់ទៅបាន ។

២១- ពត្វួនសូត្រ ប្រែបទបព្វារិត

ទេវតាភាសិត៤៣-

អ្វីជាគ្រឿងចងសត្វលោកទុកនៅ អ្វីគ្រឿងត្រេកទៅរបស់សត្វនោះ

ព្រោះលះបង់អ្វីបានដោយបំពោះ កាត់បំណងនោះទាំងអស់ទៅបាន ។

ពុទ្ធភាសិត ៤៤-

នន្ទិសម្ពន្ធនោលោកោ វិតក្កស្សវិចារណំ
តណ្ហាយ វិប្បហានេន សព្វំឆិន្ទតិពន្ធនំ ។

សេចក្ដីរីករាយចងសត្វទុកនៅ វិតក្កៈគ្រឿងទៅរបស់សត្វនោះ ព្រោះលះតណ្ហាបានដោយបំពោះ កាត់បំណងនោះទាំងអស់ទៅបាន ។

២៧ - ភីតសូត្រ ប្រែបទព្រហ្មគីត

ទេវតាភាសិត ៤៤-

ក្នុងលោកនេះគឺអ្វី　ជនប្រុសស្រីខ្លាចគ្រប់គ្នា
ទ្រង់ត្រាស់ជាមាតា　មានមែកបែកពេញច្រើនណាស់
បពិត្រព្រះគោតម　ព្រះអង្គមានបញ្ញាត្រាស់
ជនឃើញធម៌អ្វីច្បាស់　ទើបផុតភ័យក្នុងបរលោក ។

ពុទ្ធភាសិត ៤៥-

វាចំ មនញ្ច-　បណិធាយ សម្មា
កាយេន បាបា-　និ អកុព្វមានោ
ពហុន្នបានំ　ឃរមាវសន្តោ
សទ្ធោ មុទូ សំ-　វិភាគី វទញ្ញូ
ឯតេសុ ធម្មេ-　សុ ឋិតោ ចតូសុ ។

អ្នកតាំងវាចាចិត្ត　មិនប្រព្រឹត្តបាបដោយកាយ
គ្រប់គ្រងផ្ទះមានបាយ　ទឹកទាំងឡាយច្រើនអនេក ។
ជាអ្នកមានសទ្ធា　ចិត្តមេត្តាទន់ភ្លន់ពេក
បាយទឹកចែករំលែក　ហើយចេះញែកនូវពាក្យពោល។

ស្ថិតនៅក្នុងធម៌បួន(១) នឹងរូបខ្លួនព្រោះមានគោល
មិនភ័យកាលអន្ទោល ទៅកាន់បរលោកនោះឡើយ ។

២៣- កាមសូត្រ ប្រែចងបរប្បវត

ទេវតាភាសិត៤៦-

អ្វីប្រយោជន៍យើងមិនត្រូវឲ្យគេ អ្វីត្រូវរិះរេមិនគួរលះបង់
អ្វីដែលល្អសាគគួរបេញផ្ទិតផ្ទង់ អ្វីគួរបង្អង់កុំបញ្ចេញឡើយ ។

ពុទ្ធភាសិត ៤៧-

អត្តា(២)នំនទទេបោសោ អត្តានំនបរិច្ចជេ
វាចំមុញ្ចេយ្យកល្យាណឹ បាបិកញ្ជនមោចយេ ។

ប្រុសប្រាជ្ញមិនត្រូវឲ្យប្រាណ(២)ទៅគេ មិនត្រូវលះរេគិតដោយខ្លួនឯង
ពាក្យពិរោះត្រូវបេញឲ្យច្បាស់ស្ទែង ពាក្យអាក្រក់ស្ទែងកុំបញ្ចេញ-
ឡើយ ។

---

(១) ព្រហ្មវិហារ ៤ គឺមេត្តា, ករុណា, មុទិតា, ឧបេក្ខា ។

(២) អត្តស័ព្ទក្នុងទីនេះ ប្រែថាខ្លួនប្រាណ, ថាគំនិត, គឺមិនត្រូវលះការគិត មិនត្រូវប្រគល់គំនិតទៅគេទេ ឬមិនត្រូវប្រគល់ខ្លួនឲ្យគេទេព្រោះ . . . . ។

**២៤- ជាបេយ្យសូត្រ ប្រែបទបញ្ញាវ័គ**

**ទេវតាភាសិត ៤៨-**

អ្វីតែងបង់ទុកស្បៀងគឺកុសល អ្វីដែលជាផលអាស្រ័យនៃភោគ អ្វីតែងភើបទាញនរជនក្នុងលោក អ្វីជាប្រយោគសត្វលះក្រ-បាន ។

សត្វកិលេសក្រាស់អ្វីជាប់សន្តាន, ដូចបក្សីមានជើងជាប់អន្ទាក់។

**ពុទ្ធភាសិត ៤៩-**

**សទ្ធាពន្ធតិបាថេយ្យំ សិរិភោគានមាសយោ**
**ឥច្ឆានរំបរិកស្សតិ ឥច្ឆាលោកស្មិ ទុជ្ជហា**
**ឥច្ឆា ពន្ធា បុថុសត្តា បាសេន សកុណីយថា ។**

សទ្ធាបង់ទុកស្បៀងគឺកុសល សិរីជាផលអាស្រ័យនៃភោគ កិច្ចប្រាថ្នាភើបនរជនក្នុងលោក ឥច្ឆាប្រយោគលះកម្របាន ។ កិលេសក្រាស់ព្រោះឥច្ឆាជាប់ប្រាណ ដូចបក្សីមានជើងជាប់-អន្ទាក់ ។

**២៥- វិត្តសូត្រ ប្រែបទព្រហ្មគិត**

**ទេវតាភាសិត ៥០-**

អ្វីហ្នដែលជាទ្រព្យ បុរសគាប់យ៉ាងឧត្តម

អ្វីដែលគេសន្សំ　　នាំឲ្យគេបានសុខ ។
អ្វីដែលមានរស់ឆ្ងាញ់　　ជាងរស់ជាតផងនានា
ជនរស់នៅបែបណា　　ទើបឈ្មោះថារស់ប្រសើរ ។

ពុទ្ធភាសិត ៥១–

**សទ្ធីធវិត្តំ　　បុរិសស្ស សេដ្ឋំ**
**ធម្មោសុចិណ្ណោ　　សុខមាវហាតិ ។**
**សច្ចំហវេសា-　　ធុតរំរសានំ**
**បញ្ញាជីវំជី-　　វិតមាហុ សេដ្ឋំ ។**

សទ្ធានេះជាទ្រព្យ　　បុរសគាប់យ៉ាងឧត្តម
ធម៌ដែលគេសន្សំ　　នាំឲ្យគេបានសុខ
ពាក្យសត្យមានរស់ឆ្ងាញ់　　គួរស្រឡាញ់គួរស្នេហា
ជនរស់ដោយបញ្ញា　　ទើបឈ្មោះថាប្រសើរហោង ។

## ទេវតាភាសិត និង ពុទ្ធភាសិត

ចប់ដោយសង្ខេប

រោងពុម្ព គីម គី បណ្ណាគារ
លេខ៤៤ វិថីគេម៉ាដ៏មិន.ភ្នំពេញ